24 មេសា 2017



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ១ ៥៧០,៨១ ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ក្នុងនោះ (១) ដីឧទ្យានជាតិព្រះមុនីវង្ស "បូករគោ" (២)ដីគម្របព្រៃឈើឆ្នាំ ២០០២ និង ធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ចំនួន ៣៥៥ គ្រួសារ និងមួយចំណែករក្សាទុកជាដីសាធារណៈរបស់រដ្ឋ ព្រមទាំងផ្តល់សិទ្ធិ ជាកម្មសិទ្ធិលើក្បាលដី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៨៥/១៦ ល.ស ចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- លិខិតលេខ ១៨៨/១៦ ល.សចុះថ្ងៃទី ០៩ ខែមិថុនា ឆ្នាំ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ
- លិខិតលេខ ៦៨៧២ កសក ចុះថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- លិខិតលេខ ០៧៨ សជណ ប.ស្ត ចុះថ្ងៃទី ៣០ ខែ មករា ឆ្នាំ ២០១៧ របស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១ ៥៧០,៨១ ហិកតា ក្នុងនោះ (១) ទំហំ ៥៤,៣៥ ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" ដែលកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៤១៧/៣៧៦ ចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ ២០១៧ (២) ទំហំ ១ ៥១៦,៤៦ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះជាក់ស្តែងទំហំ ១ ៤០០,៣០ ហិកតា និងផ្ទៃដីទំហំ ១៧០,៥១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្ទឹងប្រាលុ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៣៥៥ គ្រួសារ នៅភូមិស្ទឹងប្រាលុ ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។

**មាត្រា ៣**: ផ្តល់សិទ្ធិជាកម្មសិទ្ធិឯកជន ចំនួន ៤១០ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ នៅ ភូមិស្ទឹងច្រាល ឃុំអូរបាក់រទេះ ស្រុកកំពង់សីលា ខេត្តព្រះសីហនុ ។

**មាត្រា ៤**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះសីហនុ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមេសា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារកាលប្បវត្តិ*

ផែនទីឧបសម្ព័ន្ធទី..០២..នៃអនុក្រឹត្យលេខ...៥៧...អនក្រ.បក........ចុះថ្ងៃទី២៤.ខែមេសា.ឆ្នាំ២០១៧ ស្តីពីការកាត់ដីទំហំ ៥៤.៣៤ហិកតា ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួន៣៦៥គ្រួសារដែលបានកាន់កាប់ប្រើប្រាស់ និងរស់នៅជាក់ស្តែងនៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ

(ភូមិស្ទឹងច្រាល ឃុំអូរបាក់រទេះ) (ខ)




តារាងនិយាមកានៃចំនុចព្រំដីស្នើសុំ

ទាញយកចំនុចដោយឧបករណ៍ Garmin GPSMap 62s

Projection UTM, Zone 48N, Datum WGS 84

ប្រភពទិន្នន័យ: ផែនទគំរបព្រៃឈើ ឆ្នាំ២០០២

| Point_ID | EASTING | NORTHING |
|---|---|---|
| 1 | 395245.021 | 1233466.117 |
| 2 | 395202.424 | 1233558.148 |
| 3 | 395234.831 | 1233557.493 |
| 4 | 395240.671 | 1233505.126 |
| 5 | 396789.472 | 1230505.253 |
| 6 | 396789.523 | 1230867.743 |
| 7 | 396841.361 | 1230875.908 |
| 8 | 397025.122 | 1230726.364 |
| 9 | 396995.101 | 1230386.405 |
| 10 | 396957.078 | 1230449.560 |
| 11 | 396929.105 | 1230410.612 |
| 12 | 396814.773 | 1230482.968 |
| 13 | 395169.746 | 1233799.119 |
| 14 | 394973.812 | 1233985.750 |
| 15 | 394726.187 | 1234164.000 |
| 16 | 394646.937 | 1234322.500 |
| 17 | 394771.218 | 1234513.701 |
| 18 | 394795.498 | 1234360.083 |
| 19 | 394814.403 | 1234338.091 |

(ទំព័រ១/២) សូមបន្តតារាងចំនុចនិយាមកានៅទំព័របន្ទាប់

ឧបសម្ព័ន្ធទី..០២..នៃអនុក្រឹត្យលេខ....៥៧...អនក្រ...បក.....ចុះថ្ងៃទី២៤...ខែមីនា ឆ្នាំ២០១៧
ស្តីពីការកាត់ដីទំហំ ៥៤.៣៤ហិកតា នៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ ចេញពីដីឧទ្យានជាតិព្រះមុនីវង្សបូកគោ
និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ គ្រួសារ

តារាងនិយាមកានៃចំនុចព្រំដីស្នើសុំ ( ទំព័រទី២/២) (ខ)

| តារាងនិយាមកានៃចំនុចព្រំដីស្នើសុំ | | |
|---|---|---|
| វាស់វែងដោយឧបករណ៍ Garmin GPSMap 62s | | |
| Projection UTM, Zone 48N, Datum WGS 84 | | |
| Point_ID | EASTING | NORTHING |
| 20 | 394933.257 | 1234274.967 |
| 21 | 394987.273 | 1234297.019 |
| 22 | 395004.023 | 1234276.506 |
| 23 | 395030.775 | 1234074.266 |
| 24 | 395159.446 | 1233989.746 |
| 25 | 396599.997 | 1230505.307 |
| 26 | 396582.071 | 1230491.008 |
| 27 | 396538.739 | 1230464.606 |
| 28 | 396532.386 | 1230458.986 |
| 29 | 396441.890 | 1230471.329 |
| 30 | 396434.966 | 1230457.639 |
| 31 | 396358.152 | 1230308.924 |
| 32 | 395797.285 | 1230321.714 |
| 33 | 395728.636 | 1230323.279 |
| 34 | 395809.831 | 1230456.112 |
| 35 | 396206.862 | 1230626.362 |
| 36 | 396396.112 | 1230568.112 |
| 37 | 396706.713 | 1232451.982 |
| 38 | 396575.906 | 1232413.378 |
| 39 | 396390.187 | 1232475.259 |
| 40 | 396303.531 | 1232586.750 |
| 41 | 396055.906 | 1232648.625 |
| 42 | 395882.562 | 1232846.750 |
| 43 | 395820.419 | 1232894.257 |
| 44 | 396161.304 | 1232847.742 |
| 45 | 396174.796 | 1232841.129 |
| 46 | 396362.877 | 1232706.540 |
| 47 | 396382.673 | 1232682.037 |
| 48 | 396472.018 | 1232755.[illegible] |
| 49 | 396554.823 | 1232696.084 |
| 50 | 396614.337 | [illegible] |
| 51 | 396655.953 | 1232732.586 |
| 52 | 396737.435 | 1232498.324 |
| 53 | 396709.620 | 1232474.084 |